MINISTRY OF ECONOMY AND FINANCE

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ២៥៤២ សហវ.លទក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១៧

**សូមគោរពជូន**

**លោកជំទាវឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**

**កម្មវត្ថុ:** ករណីសំណើសុំពិនិត្យនិងសម្រេចប្រគល់កិច្ចសន្យាស្តីពីការងារសាងសង់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចំនួន ០១ខ្នង នៅខេត្តកំពង់ធំ។

**យោង:**
- លិខិតលេខ ១៤៣០សហវ.អថ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កំណត់ហេតុបើកឯកសារដេញថ្លៃនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ និងកំណត់ហេតុវាយតម្លៃនិងប្រគល់កិច្ចសន្យានៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ របស់គណៈកម្មាធិការលទ្ធកម្មក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- លិខិតលេខ ២៩០/១៧ ទ រ ព អ.រប ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូនលោកជំទាវឧបនាយករដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការប្រគល់កិច្ចសន្យាជូនសហគ្រាស មង្គល ចំរើនពាណិជ្ជ ដើម្បីធ្វើការងារសាងសង់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពង់ធំ ចំនួន ០១ខ្នង ក្នុងតម្លៃសរុបចំនួន ៧៩៥ ៩៦២ ០០០រៀល ( ប្រាំពីររយកៅសិបប្រាំលាន ប្រាំបួនរយហុកសិបពីរពាន់រៀលគត់) ជាតម្លៃកិច្ចសន្យា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកជំទាវឧបនាយករដ្ឋមន្ត្រីមេត្តាជ្រាបនិងមានវិធានការអនុវត្តបន្តឲ្យបានសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមលោកជំទាវឧបនាយករដ្ឋមន្ត្រីទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ក. ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
រដ្ឋលេខាធិការ

ជួ ឌីជិត្ត

**ចម្លងជូន:**
- អគ្គនាយកដ្ឋានពន្ធដារ
- អគ្គនាយកដ្ឋានថវិកា
- សាលាខេត្តកំពង់ធំ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ធំ
- មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តកំពង់ធំ
- សហគ្រាស មង្គល ចំរើនពាណិជ្ជ
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798